ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌលេខ: ២១៥
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩
សាលក្រមលេខ: ៣៤/០៧ (ក)
ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

សាលក្រមនេះ បានចូលជាស្ថាពរចំពោះមុខឈ្មោះ HAI LIANG, ឈ្មោះ YANG KE, ឈ្មោះ HU CHENG XIANG, ឈ្មោះ CHEN YI និងឈ្មោះ XIE QING GEN រួចហើយកាលពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២០ ។

[redacted]

បានឃើញ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៨/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៨ ។

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តព្រះសីហនុនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០២០ វេលាម៉ោងពីរ និងសាមសិបនាទីរសៀល ដែលមានសមាសភាពចូលរួម ៖

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា
-លោក [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារង

## ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ជាក្រឡាបញ្ជីសវនាការ

**ដើម្បីជំនុំជម្រះ ៖**

សំណុំរឿងព្រហ្មទណ្ឌលេខ **២១៥** ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted]លៀង ([redacted] LIANG) ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិចិនដីគោកទីកន្លែងកំណើតនៅខេត្តហ៊ូប៉ៃ ប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះសំណាក់លូចាំងសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកបើកឡានឲ្យក្រុមហ៊ុនស៊ាងជុង



Scanned with CamScanner

នោលិះ ឪពុកឈ្មោះ [redacted] HUA (រ) ម្ដាយឈ្មោះ [redacted] BO (រ) ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៧៨៤ ត.ព.ជ/១៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

២.ឈ្មោះ [redacted] ខឺ ([redacted] KE) ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិចិនដីគោក ទីកន្លែងកំណើតនៅខេត្តហ៊ូឡាំង ប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួននៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកជូនភ្ញៀវមើលផ្ទះ និងដីជួល ប្រពន្ធឈ្មោះ [redacted] MIN មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] YONG QIANG (រ) ម្ដាយឈ្មោះ [redacted] XI QIOU (រ) ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៧៨៦ ត.ព.ជ/១៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៣.ឈ្មោះ [redacted] ឆេងយ៉ាង ([redacted] CHENG XIANG) ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិនដីគោក ទីកន្លែងកំណើតនៅខេត្តហ៊ូណាន ប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះសំណាក់ឡុងចិនហ័រសាង សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ មិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] DE TIAM មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] ZHENG QUAN (រ) ម្ដាយឈ្មោះ [redacted] SI HUA (រ) ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៧៨០ ត.ព.ជ/១៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៤.ឈ្មោះ [redacted] អ៊ី ([redacted] YI) ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិចិនទីកន្លែងកំណើតនៅប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួននៅយ៉ាម៉ារសេតេ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ ជាងជួសជុលម៉ាស៊ីន ប្រពន្ធឈ្មោះ WANG LI មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] RUO MING (រ) ម្ដាយឈ្មោះ [redacted] MAI QIU (រ) ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៧៨២ ត.ព.ជ/១៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

៥.ឈ្មោះ [redacted] ឈិងកិន ([redacted] QING GEN) ភេទប្រុស អាយុ ២៤ឆ្នាំ ជនជាតិចិនដីគោក ទីកន្លែងកំណើតនៅខេត្តចាំងស៊ី ប្រទេសចិន ទីលំនៅមុនពេលឃុំខ្លួននៅយ៉ាម៉ារ

សេតេ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មុខរបរ អ្នកលក់គ្រឿងទេស ប្រពន្ធឈ្មោះ [redacted]JIA (លែងលះ) មានកូន ០១នាក់ ឪពុកឈ្មោះ [redacted] YUN HOU (រ) ម្តាយឈ្មោះ [redacted]HU XU (រ) ជាទីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៧៨៨ ត.ព.ជ/១៩ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តព្រះសីហនុ ។

ត្រូវបានចោទប្រកាន់ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ:**

១. លោកមេធាវី [redacted] មានការិយាល័យអគារលេខ ៣៥CD ផ្ទះលេខ២៧១ ក្រុម០៧ ភូមិបឹងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

២. លោកមេធាវី [redacted] មានការិយាល័យនៅភូមិ៣ សង្កាត់លេខ ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៣. លោកមេធាវី [redacted] មានការិយាល័យនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។

៤. លោកស្រីមេធាវី [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅផ្ទះលេខ៣៤ ផ្លូវ១០ម៉ែត្រ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

## ១.អង្គហេតុនៃបណ្តឹងចោទប្រកាន់

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០២ និង៤៥ នាទីព្រឹក ស្ថិតនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានករណី គ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង បន្ទាប់មកនៅពេលដែលសមត្ថកិច្ចចុះធ្វើអន្តរាគមន៍នៅទីតាំងកើតហេតុ ក៏ប្រទះឃើញគ្រឿងញៀនចំនួន ០៨កញ្ចប់ធំ និងបានឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ[redacted]LIANG ភេទប្រុស ជនជាតិចិន ចំណែកបក្ខពួកពីរនាក់ទៀត ដែលរួមដំណើរជាមួយគ្នាមានឈ្មោះ [redacted] HAI YIN ហៅ A HUA និងឈ្មោះ [redacted] SI PIN ហៅ A DONG បានរត់គេចខ្លួនចូលព្រៃបាត់ ។ លុះមួយសន្ទុះក្រោយមក សមត្ថកិច្ចក៏ប្រទះឃើញ



Scanned with CamScanner

រថយន្តមួយគ្រឿងទៀតបើកបរដោយជនជាតិចិន ក្នុងល្បឿនលឿនមានគ្នាបីនាក់ ដោយមានការសង្ស័យ សមត្ថកិច្ចក៏ដេញតាមចាប់បាននៅជិតវត្តស្ពាច់ដែង ស្ថិតក្នុងភូមិស្ពាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយចាប់បានជនសង្ស័យម្នាក់ឈ្មោះ [redacted] KE ភេទប្រុស ជនជាតិចិន និងរកឃើញមានសារធាតុញៀនចំនួន ១៦កញ្ចប់បន្ថែមទៀត សរុបទាំងអស់ជនសង្ស័យទាំងពីរនាក់ខាងលើ ចាប់បានថ្នាំញៀនកេតាមីន (ខេ) ចំនួន ០១កញ្ចប់ធំ ទម្ងន់ ៤៩៩.៤៨ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនកេតាមីន (ខេ) ០១កញ្ចប់តូច ទម្ងន់ ១៤.៤២ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនមេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់ ទម្ងន់ ២៦៦.៣១ក្រាម (ទម្ងន់សុទ្ធ) និងរថយន្ត ០២គ្រឿង ម៉ាក RX 300 និងម៉ាក Prius ពណ៌ទឹកប្រាក់ ។ បន្ទាប់ពីធ្វើការសាកសួរលើឈ្មោះ [redacted] KE ភេទប្រុស ទើបសមត្ថកិច្ចឈានដល់ការចាប់ខ្លួនបក្ខពួកចំនួន ០៣នាក់ទៀត រួមមានឈ្មោះ [redacted] CHENG XIANG ភេទប្រុស ជនជាតិចិន, ឈ្មោះ [redacted] YI ភេទប្រុស ជនជាតិចិន ដកហូតបានថ្នាំញៀនកេតាមីន (ខេ) ចំនួន ០១កញ្ចប់ ទម្ងន់ ១០៤.៩២ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនមេតំហ្វេតាមីន (WY) ០២គ្រាប់ ទម្ងន់ ០.១៨ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនអ៊ិចស្តាស៊ី វេចខ្ចប់ថង់ផ្លាស្ទិចពណ៌ខ្មៅ និងមានសញ្ញាសម្គាល់អក្សរ (V) ចំនួន ០២កញ្ចប់ ទម្ងន់ ៥.៦៦ក្រាម គិតទាំងកញ្ចប់ ជញ្ជីងសម្រាប់ថ្លឹង ចំនួន ០២ ថង់សម្រាប់វេចខ្ចប់គ្រឿងញៀនចំនួន ០៦ដុំ និងរថយន្ត ០១ គ្រឿង ម៉ាក LX 300 ពណ៌ស និងឈ្មោះ XIE QING GEN ភេទប្រុស ជនជាតិចិន ព្រមទាំងដកហូតបានថ្នាំញៀនកេតាមីន (ខេ) ចំនួន ០១កញ្ចប់ ទម្ងន់ ១.៩៣ក្រាម (ទម្ងន់សុទ្ធ) និងទូរស័ព្ទ ០១គ្រឿង ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤២៥២ ត.ព/១៩ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ ។

## ២. នីតិវិធីនៃសវនាការ

### ២.១ ការស្តាប់ចម្លើយរបស់ជនជាប់ចោទ:

**២.១.១** *ជនជាប់ចោទឈ្មោះ* [redacted] លៀង [redacted] LIANG) *បានឆ្លើយថា:* សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយសារគ្រោះថ្នាក់ចរាចរណ៍ ខ្លួនបានបើកឡានបុកឡានដែលចតនៅតាមផ្លូវ ដោយពេលសមត្ថកិច្ចឃាត់ខ្លួន គឺឃាត់តែម្នាក់ឯងទេ ហើយបានធ្វើការឆែកឆេរខ្លួន ដកហូតបានទូរស័ព្ទចំនួន ០២ គ្រឿង និងលុយមួយចំនួន ប៉ុន្តែមិនមានថ្នាំញៀនទេ ។ បន្ទាប់មកសមត្ថកិច្ចបានបន្តឆែករថយន្តរបស់ខ្លួនម៉ាក Toyota ពណ៌ទឹកប្រាក់ ក៏មិនមានថ្នាំញៀនដែរ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] Ke ទេ ។ ចំពោះវត្ថុតាងដែល

សមត្ថកិច្ចឱ្យខ្លួនផ្តិតមេដៃទទួលស្គាល់ គឺខ្លួនមិនបានដឹងទេ ព្រោះថាពេលសមត្ថកិច្ចឃាត់ខ្លួនមិនបានដកហូតថ្នាំញៀនពីខ្លួននោះទេ ។ ខ្លួនមិនចេះភាសាខ្មែរ ដូច្នេះគេឱ្យខ្លួនផ្តិត គឺខ្លួនចេះតែផ្តិតទៅ។

**២.១.២** *ជនជាប់ចោទឈ្មោះ* [redacted] **ខឺ (YANG KE)** *បានឆ្លើយថា:* ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ៤ ទៅ ៥ ទាបភ្លឺនៅចំណុចផ្លូវជាតិលេខ៤ ជិតដល់ព្រលានយន្តហោះ ដោយពេលសមត្ថកិច្ចឃាត់ខ្លួន គឺឃាត់តែម្នាក់ឯងទេ ហើយបានធ្វើការឆែកឆេរ និងដកហូតបានទូរស័ព្ទ ០២ គ្រឿង ចំពោះថ្នាំញៀន គឺមិនមានទេ ។ ខ្លួនជិះរថយន្តម៉ាក Lexus RX300 ពណ៌ខ្មៅ ។ មុនពេលសមត្ថកិច្ចឃាត់ខ្លួន គឺមានគេពឹងឱ្យខ្លួនបើកឡានទៅយកនៅចំណុចផ្លូវជាតិលេខ៤ នៅចំណុចគ្រោះថ្នាក់ចរាចរណ៍ ដោយបានដឹក A Dong និង A Hua ដោយពេលកំពុងធ្វើដំណើរឆ្ពោះទៅខេត្តព្រះសីហនុ ជិតដល់ព្រលានយន្តហោះ ប៉ូលីសបានហៅឡានឈប់ A Dong និង A Hua បានរត់គេចខ្លួន ហើយខ្លួនក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ សមត្ថកិច្ចឆែកឆេរឡានរបស់ខ្លួន គឺគ្មានថ្នាំញៀនទេ ។ ខ្លួនមិនស្គាល់ឈ្មោះ [redacted] Liang ទេ ហើយក៏មិនត្រូវបានចាប់ខ្លួនជាមួយគ្នាដែរ ។ ចំពោះការផ្តិតមេដៃទទួលស្គាល់វត្ថុតាងនៅសមត្ថកិច្ច គឺខ្លួនមិនទទួលស្គាល់ទេ ព្រោះមិនមានអ្នកបកប្រែប្រាប់ថាផ្តិតលើអ្វី ពេលនោះខ្លួនចេះតែផ្តិតទៅ ។ ថ្នាំញៀននោះមិនមែនជារបស់ខ្លួនទេ ។

**២.១.៣** *ជនជាប់ចោទឈ្មោះ* [redacted] ចេងយ៉ាង [redacted] **CHENG XIANG)** *បានឆ្លើយថា:* ខ្លួនស្គាល់ឈ្មោះ [redacted] Yi តែមិនស្គាល់ឈ្មោះ [redacted] ke ទេ ។ ខ្លួន និងឈ្មោះ [redacted] Yi បានចូលរួមគ្នាលក់ថ្នាំញៀន ដោយបានទិញនៅភ្នំពេញ ប៉ុន្តែមិនដែលទិញពីឈ្មោះ [redacted] Ke ទេ ។ ខ្លួនជាមិត្តភក្តិឈ្មោះ [redacted] Qing Gen ធ្លាប់ចែកឱ្យប្រើ តែមិនបានលក់ទេ ។ ខ្លួនរស់នៅជាមួយឈ្មោះ [redacted] Qing Gen មិនបានចូលរួមលក់នោះទេ ។ ពួកខ្លួនស្នាក់នៅជាមួយគ្នាប្រហែល ០១ ខែជាងហើយ ។ គ្រឿងញៀន ០៣ កញ្ចប់ ជារបស់ឈ្មោះ [redacted] Qing Gen គឺរកឃើញក្នុងហោប៉ៅរបស់វា ចំណែកគ្រឿងញៀនរបស់ខ្លួន និងឈ្មោះ [redacted] Yi គឺទុកក្នុងទូ ។ គ្រឿងញៀនទិញមក គឺដាក់ចូលគ្នាជាមួយឈ្មោះ [redacted] Yi ។ ពេលសមត្ថកិច្ចឃាត់ខ្លួន គឺដកហូតបានថ្នាំញៀនចំនួន ១០០ កញ្ចប់ ពីឈ្មោះ [redacted] Yi និងខ្លួន ។ ថ្នាំញៀនរបស់ខ្លួនមានចំនួន ៥២ កញ្ចប់ និងរបស់ឈ្មោះ [redacted] Yi មានចំនួន ៥០ កញ្ចប់ ចំណែកឈ្មោះ [redacted] Gen គឺមាន ០៣ កញ្ចប់ ផ្សេងទៀត ។ ឈ្មោះ [redacted] Qing Gen យកថ្នាំពីក្នុងទូមកប្រើ ដោយមិនបានលក់ឱ្យទេ ហើយក៏មិនធ្លាប់ប្រើឱ្យវាយកថ្នាំឱ្យគេដែរ ។

**២.១.៤** *ជនជាប់ចោទឈ្មោះ* [redacted] យី [redacted] YI) *បានឆ្លើយថាៈ* ខ្លួនបានទិញមកថ្នាំញៀនមកហើយ តែមិនទាន់ចាប់ផ្ដើមលក់ទេ ខ្លួនស្គាល់ឈ្មោ[redacted]Cheng Xiang ព្រោះខ្លួនរស់នៅជាមួយគ្នា ។ ការរកស៊ីគឺបែងចែកដាច់ពីគ្នា គាត់ជាអ្នកលក់ចំណេញផ្សេង ខ្លួនចំណេញផ្សេង ។ ខ្លួនទិញថ្នាំពីអ្នកស្គាល់នៅភ្នំខៀវ ។ ខ្លួនស្គាល់ឈ្មោះ [redacted] Qing Gen តែមិនដែលលក់ឱ្យគាត់ទេ តែឈ្មោះនេះធ្លាប់យកថ្នាំទៅប្រើប្រាស់ ។ ពួកខ្លួនមានគ្នា ០៣ នាក់ គឺរស់នៅជាមួយគ្នា ឈ្មោះ [redacted] Qing Gen គ្រាន់តែប្រើប្រាស់ថ្នាំញៀន គឺមិនបានលក់នោះទេ ។ ឈ្មោះ [redacted] Qing Gen យកថ្នាំញៀនទៅប្រើគឺមិនបានឱ្យលុយនោះទេ ។ សមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនចំនួន ៥០ កញ្ចប់ និងដកហូតពីឈ្មោះ [redacted] Cheng Xiang ចំនួន ៥២ កញ្ចប់ ។

**២.១.៥** *ជនជាប់ចោទឈ្មោះ* [redacted] សិងកិន [redacted] QING GEN) *បានឆ្លើយថាៈ* សមត្ថកិច្ចឃាត់ខ្លួននៅផ្ទះសំណាក់ ហ័រសៀ ប្រហែលម៉ោង ១០ និង៣០នាទីព្រឹក ខ្លួនស្នាក់នៅជាមួយឈ្មោះ [redacted] Cheng Xiang និងឈ្មោះ [redacted] Yi ។ ខ្លួនទាំង ០៣ នាក់ គឺចាប់ពេលជាមួយគ្នា ហើយសមត្ថកិច្ចដកហូតថ្នាំញៀនពីខ្លួនបានចំនួន ០៣ កញ្ចប់តូច ទម្ងន់ ១.៩៣ ក្រាម ប្រភេទ ខេ ខ្លួនយកចេញមកពីទូ ជារបស់ឈ្មោះ [redacted] Yi ។

**២.២ ការស្ដាប់សេចក្ដីសន្និដ្ឋានទោសរបស់តំណាងអយ្យការ:** ឆ្លងតាមដេញដោលក្នុងអង្គសវនាការឃើញថា ជនជាប់ចោទខ្លះបានសារភាពហើយ ជនជាប់ចោទខ្លះបានព្យាយាមបដិសេធនិងដោះសារ ទោះបីជាយ៉ាងណាក៏ដោយ យើងពិនិត្យលើភស្តុតាងទាំងមូល និងលទ្ធផលកោសល្យវិច័យ ឃើញថា ជនជាប់ចោទខាងលើ គឺជាក្រុមជនទុច្ចរិតដែលរកស៊ីគ្រឿងញៀនជាបណ្ដាញ ដូច្នេះតំណាងអយ្យការធ្វើការតម្កល់ដីកាសន្និដ្ឋានស្ថាពរ និងសុំឱ្យតុលាការមេត្តាសម្រេចផ្ដន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ។

**២.៣ ការស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី វៀន ពិសី ការពារសិទ្ធិឱ្យជនជាប់ចោទ៖** ឆ្លងតាមការដេញដោលក្នុងអង្គសវនាការឃើញថា កូនក្ដីខ្លួនឈ្មោះ [redacted] Liang ពុំបានប្រព្រឹត្តការជួញដូរគ្រឿងញៀននោះទេ គ្រាន់តែជាអ្នកបើកឡានឱ្យគេជាថ្នូរនឹងលុយចំនួន ២០០ ដុល្លារ ក្នុងការធ្វើដំណើរទៅមក គឺមិនមានពាក់ព័ន្ធថ្នាំញៀននោះទេ ។ ដោយយើងឃើញថា កំណត់ហេតុគ្មានស្នាមមេដៃរបស់អ្នកបកប្រែនោះទេ ។ សរុបសេចក្ដីមកឃើញថា ក្នុងអង្គហេតុខាងលើ ពុំមានភស្តុតាងដើម្បីដាក់បន្ទុកលើកូនក្ដីខ្លួនទេ ដូច្នេះស្នើសុំឱ្យតុលាការមេត្តាសម្រេចឱ្យឈ្មោះ [redacted] Liang រួចផុតពីបទចោទ និងដោះលែងកូនក្ដីខ្លួនឱ្យមានសេរីភាពវិញ ផ្អែកតាមការដេញដោលលើឈ្មោះ [redacted] Qing Gen គឺនៅពេលដែលសមត្ថកិច្ចចុះធ្វើការឆែកឆេរ គឺគាត់កំពុងដេក ដោយសមត្ថកិច្ចដកហូតបានថ្នាំ ០៣ កញ្ចប់តូច ដូច្នេះខ្លួន



Scanned with CamScanner

ស្នើសុំឱ្យតុលាការមេត្តាសម្រេចប្តូរបទចោទពីបទ សមគំនិតជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកបទរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀនវិញ ។

២.៤ **ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ៖** ចូលតាមការដេញដោលមកនេះឃើញថា ឈ្មោះ [redacted] Yi ឈ្មោះ [redacted] Cheng Xiang និងឈ្មោះ [redacted] Qing Gen ពាក់ព័ន្ធនឹងថ្នាំញៀន គឺជាប្រភេទថ្នាំសប្បាយការប្រព្រឹត្តនេះ គឺដើម្បីដោះដូរបានប្រាក់កំរៃតិចតួចប៉ុណ្ណោះ ដោយចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូត ដូចកូនក្តីខ្ញុំបានបញ្ជាក់គឺ ៥២ កញ្ចប់ ជារបស់ឈ្មោះ [redacted] Cheng Xiang និងឈ្មោះ ៥០ កញ្ចប់ ជារបស់ឈ្មោះ [redacted] yi ។ ដោយសារតែកូនក្តីខ្ញុំលេងល្បែងចាញ់ ទើបចាញ់បោកគេ ម្យ៉ាងវិញទៀត កូនក្តីខ្ញុំឈ្មោះ [redacted] Yi និងឈ្មោះ [redacted] Cheng Xiang បានសារភាពហើយ ហើយនេះជាកំហុសទី១ ដូច្នេះសំណូមពរឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំផង ។

២.៥ **ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ៖** ក្រោយពីការដេញដោលយោងតាមចម្លើយឈ្មោះ [redacted] Ke បានបញ្ជាក់ថា ខ្លួនគ្រាន់តែជាអ្នកបើកបរ ដែលទៅទទួលឈ្មោះ [redacted] Dong និងឈ្មោះ [redacted] Hua តែប៉ុណ្ណោះ ដោយមិនមានភស្តុតាងបញ្ជាក់ថាឈ្មោះ Yang Ke ជាអ្នករកស៊ីថ្នាំញៀននោះទេ ឬបានដឹងនោះទេ ។ ការធ្វើដំណើរទៅកាន់ខេត្តព្រះសីហនុ ឈ្មោះ [redacted] Dong និងឈ្មោះ [redacted] ua បានយករបស់ក្នុងឈ្មោះ [redacted] Ke ឱ្យឈប់ឡានដើម្បីឱ្យអ្នកទាំងពីររត់គេចខ្លួន ដោយនៅពេលសមត្ថកិច្ចឆែករថយន្តគឺឃើញថ្នាំញៀននៅទ្វារក្រោយរថយន្ត ដោយកូនក្តីខ្ញុំជាអ្នកបើកឡាន ហើយឈ្មោះ [redacted] Dong និងឈ្មោះ [redacted] Hua នៅអង្គុយក្រោយ ដូច្នេះថ្នាំញៀនទាំងនោះអាចជារបស់ឈ្មោះ [redacted] Dong និងឈ្មោះ [redacted] Hua ។ មួយវិញទៀត កូនក្តីខ្ញុំមិនអាចបើកឡានយកថ្នាំញៀនទៅជាមួយនោះទេ ជារឿងដែលមិនអាចកើតឡើង ។ ហើយក្រលេកមើលកំណត់ហេតុ និងសំណុំរឿងដែលសមត្ថកិច្ចសាងមកឃើញថា រកឃើញថ្នាំញៀន ០៨ កញ្ចប់ ក្នុងឡានរបស់ឈ្មោះ [redacted] Liang និងថ្នាំញៀន ១៦ កញ្ចប់ ក្នុងឡានរបស់ឈ្មោះ [redacted] Ke ដោយពេលធ្វើកំណត់ហេតុដកហូត មិនបានធ្វើការបែងចែកទេ គឺដាក់ចូលគ្នាតែម្តង ។ ក្នុងអង្គហេតុកូនក្តីរបស់ខ្ញុំ គឺមានភាពស្រពិចស្រពិលមិនច្បាស់លាស់ ដូច្នេះវិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ និងសូមឱ្យតុលាការមេត្តាលើកលែងចោទប្រកាន់ឱ្យគាត់ផង ។

២.៦ **ការស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ:** ក្រោយពីបានស្តាប់ការដេញដោលក្នុងអង្គសវនាការមកនេះ កូនក្តីខ្ញុំឈ្មោះ [redacted] Yi និងឈ្មោះ

[redacted] Cheng xiang បានសារភាព និងទទួលស្គាល់ទោសកំហុសរបស់ខ្លួន ដូច្នេះស្នើសុំឱ្យតុលាការមេត្តាពិចារណាលើស្ថានសម្រាលទោសលើកូនក្តីខ្លួនផង ។

២.៧ **ការស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ:** សូមតុលាការបន្ធូរបន្ថយទោសឱ្យពួកខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចុងក្រោយមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាងនានាក្នុងសំណុំរឿង

-បានឃើញ កំណត់ហេតុជំនុំជម្រះចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តព្រះសីហនុ ។

## ៣.ផ្នែកសំអាងហេតុ

## ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់
## សាលាដំបូងខេត្តព្រះសីហនុ យល់ឃើញថា ៖

៣.១ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ៤៤៥៤ ត.ព/១៩ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៩[1] ចៅក្រមស៊ើបសួរបានសម្រេចប្តឹងចោទប្រកាន់លើជនជាប់ចោទ៖ ១.ឈ្មោះ [redacted] លៀង [redacted] LIANG) ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិចិនដីគោក, ២.ឈ្មោះ [redacted] ខឺ [redacted] KE) ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិចិនដីគោក, ៣.ឈ្មោះ [redacted] ឆេងយ៉ាង [redacted] CHENG XIANG) ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិនដីគោក, ៤.ឈ្មោះ [redacted] អ៊ី [redacted] YI) ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិចិន និង ៥.ឈ្មោះ [redacted] ស៊ីងកិន [redacted] QING GEN) ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិចិន មកជំនុំជម្រះ ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តៈនាចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៨ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣.២ អំពើល្មើសដែលរងការចោទប្រកាន់ត្រូវបានប្រព្រឹត្តឡើងនៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១៩ ដូច្នេះអំពើនេះត្រូវស្ថិតក្នុងវិសាលភាព នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងក្រមព្រហ្មទណ្ឌ ។

---

[1] ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៤៥៤ ត.ព ១៩ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ។ (ឯកសារលេខ ៥៣)



Scanned with CamScanner

៣.៣ តាមរបាយការណ៍លេខ ០៤៤ រ.ប.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩[9] របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ថា កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០២ និង៤៥ នាទីព្រឹក ស្ថិតនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានករណី គ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង បន្ទាប់មកនៅពេលដែលសមត្ថកិច្ចចុះធ្វើអន្តរាគមន៍នៅទីតាំងកើតហេតុ ក៏ប្រទះឃើញគ្រឿងញៀនចំនួន ០៨កញ្ចប់ធំ និងបានឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ [redacted] LIANG ភេទប្រុស ជនជាតិចិន ចំណែកបក្ខពួកពីរនាក់ទៀត ដែលរួមដំណើរជាមួយគ្នាមានឈ្មោះ [redacted] HAI [redacted] ហៅ [redacted] HUA និងឈ្មោះ [redacted] SI PIN ហៅ [redacted] DONG បានរត់គេចខ្លួនចូលព្រៃបាត់ ។ លុះមួយសន្ទុះក្រោយមក សមត្ថកិច្ចក៏ប្រទះឃើញរថយន្តមួយគ្រឿងទៀតបើកបរដោយជនជាតិចិន ក្នុងល្បឿនលឿនមានគ្នាបីនាក់ ដោយមានការសង្ស័យ សមត្ថកិច្ចក៏ដេញតាមចាប់បាននៅជិតវត្តស្មាចដែង ស្ថិតក្នុងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយចាប់បានជនសង្ស័យម្នាក់ឈ្មោះ [redacted] KE ភេទប្រុស ជនជាតិចិន និងរកឃើញមានសារធាតុញៀនចំនួន ១៦ កញ្ចប់បន្ថែមទៀត សរុបទាំងអស់ជនសង្ស័យទាំងពីរនាក់ខាងលើ ចាប់បានថ្នាំញៀនឈ្មោះ កេតាមីន (ខេ) ចំនួន ០១កញ្ចប់ធំ ទម្ងន់ ៤៩៩.៤៨ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀន ឈ្មោះ កេតាមីន (ខេ) ០១កញ្ចប់តូច ទម្ងន់ ១២.៤២ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនឈ្មោះ មេតំហ្វេតាមីន (ICE) ចំនួន ០១កញ្ចប់ ទម្ងន់ ៤៦៦.៣១ ក្រាម (ទម្ងន់សុទ្ធ) និងរថយន្ត ០២គ្រឿង ម៉ាក RX 300 និងម៉ាក Prius ពណ៌ទឹកប្រាក់ ។ បន្ទាប់ពីធ្វើការសាកសួរលើឈ្មោះ YANG KE ភេទប្រុស ទើបសមត្ថកិច្ចឈានដល់ការចាប់ខ្លួនបក្ខពួកចំនួន ០៣នាក់ទៀត រួមមានឈ្មោះ [redacted] CHENG XIANG ភេទប្រុស ជនជាតិចិន, ឈ្មោះ [redacted] YI ភេទប្រុស ជនជាតិចិន ដកហូតបានថ្នាំញៀនកេតាមីន (ខេ) ចំនួន ០១កញ្ចប់ ទម្ងន់ ១០២.៩២ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀនមេតំហ្វេតាមីន (WY) ០២គ្រាប់ ទម្ងន់ ០.១៨ក្រាម (ទម្ងន់សុទ្ធ) ថ្នាំញៀន អ៊ិចស្តាស៊ី រេចខ្ចប់ចងផ្លាស្ទិចពណ៌ខ្មៅ និងមានសញ្ញាសម្គាល់អក្សរ (V) ចំនួន ០២កញ្ចប់ ទម្ងន់ ៥.៦៦ក្រាម គិតទាំងកញ្ចប់ ជញ្ជីងសម្រាប់ថ្លឹង ចំនួន ០២ ចង់

[9] របាយការណ៍លេខ ០៤៤ រ.ប.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ស្នងការនគរបាលខេត្តព្រះសីហនុ ។ (ឯកសារលេខ ១)

សម្រាប់វេចខ្ចប់គ្រឿងញៀនចំនួន ០៦ដុំ និងរថយន្ត ០១គ្រឿង ម៉ាក LX 300 ពណ៌ស និងឈ្មោះ [redacted] QING GEN ភេទប្រុស ជនជាតិចិន ព្រមទាំងដកហូតបានថ្នាំញៀនឈ្មោះ កេតាមីន (ខេ) ចំនួន ០១កញ្ចប់ ទម្ងន់ ១.៩៣ក្រាម (ទម្ងន់សុទ្ធ) និងទូរស័ព្ទ ០១គ្រឿង ។

៣.៤ តាមរបាយការណ៍លេខ ០៤៤ រ.ប.ក ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ការិយាល័យនគរបាលប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ត្រង់ផ្នែកសេចក្តីសន្និដ្ឋាន បានបញ្ជាក់ផងដែរថា ឈ្មោះ Hai Liang , ឈ្មោះ [redacted] Ke , ឈ្មោះ [redacted] ChengXiang និងឈ្មោះ [redacted] Yi បានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន បទល្មើសនេះប្រព្រឹត្តឡើងបំពាននៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។ ចំណែកឈ្មោះ [redacted] Qing Gen ពិតជាបានប្រព្រឹត្តបទល្មើស សមគំនិតក្នុងបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន បទល្មើសនេះប្រព្រឹត្តឡើងបំពាននៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននៅកម្ពុជា ។

៣.៥ យោងតាមលទ្ធផលនៃការជេញដោល តុលាការពិចារណាឃើញថា៖

- **អំពើជនជាប់ចោទឈ្មោះ [redacted] Liang ៖**
  - តាមចម្លើយរបស់ជនជាប់ចោទរូបនេះ នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែចម្លើយដោះសារបែបនេះ មិនអាចឱ្យតុលាការជឿជាក់បានទេ ដោយហេតុថាផ្អែកតាមចម្លើយរបស់ជនជាប់ចោទរូបនេះ នៅដំណាក់កាលអយ្យការបានឆ្លើយបញ្ជាក់ថា នៅថ្ងៃកើតហេតុ ខ្លួនបានដឹកឈ្មោះ [redacted] Dong និងឈ្មោះ [redacted] Hau ទៅភ្នំពេញដើម្បីយកគ្រឿងញៀន ពេលយកបានហើយក៏ត្រលប់មកខេត្តព្រះសីហនុវិញ ដោយនៅតាមផ្លូវបានជួបនឹងគ្រោះថ្នាក់ចរាចរណ៍ រួចហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង ។ ទន្ទឹមនឹងនេះ តាមចម្លើយរបស់ជនជាប់ចោទរូបនេះ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ នៃស្នងការនគរបាលខេត្តព្រះសីហនុ បានបញ្ជាក់ដែរថា ខ្លួនបានដឹកឈ្មោះ [redacted] Dong និង ឈ្មោះ [redacted] Hau ទៅភ្នំពេញដើម្បីយកគ្រឿងញៀន ពេលទៅដល់ភ្នំពេញ ឈ្មោះ [redacted] Hau បានទូរស័ព្ទ

ទៅម្ចាស់ឥវ៉ាន់(គ្រឿងញៀន) លឺគេប្រាប់ថា ឱ្យទៅយកថ្នាំញៀននៅកាស៊ីណូ ។ ក្រោយពីបានថ្នាំញៀនហើយ ពួកខ្លួនក៏ត្រលប់មកខេត្តព្រះសីហនុវិញ ដោយនៅតាមផ្លូវបានជួបនឹងគ្រោះថ្នាក់ចរាចរណ៍ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបានតែម្តង ចំណែកឈ្មោះ [redacted] Dong និងឈ្មោះ [redacted] Hua សមត្ថកិច្ចមិនបានចាប់ពួកគេបានទេ ដោយសារពួកគេរត់គេចខ្លួនបាត់ ។

- យោងតាមសំអាងហេតុខាងលើ មានភាពស៊ីសង្វាក់ទៅនឹងវត្ថុតាងជាគ្រឿងញៀន ដែលសមត្ថកិច្ចបានដកហូតពីក្នុងរថយន្តរបស់ជនជាប់ចោទឈ្មោះ [redacted] Liang ដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុដកហូតសម្ភារៈវត្ថុតាងចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បានរំលេចឱ្យឃើញថាជនជាប់ចោទឈ្មោះ [redacted] Liang គឺជាសហចារីក្នុងការប្រព្រឹត្តបទល្មើសជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

- **អំពើជនជាប់ចោទឈ្មោះ [redacted] Ke ៖**
  - តាមចម្លើយរបស់ជនជាប់ចោទរូបនេះ នៅគ្រប់ដំណាក់កាលបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ តែចម្លើយដោះសារបែបនេះ មិនអាចឱ្យតុលាការជឿជាក់បានទេ ដោយហេតុថាផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] Cheng Xiang និងឈ្មោះ [redacted] Yi នៅគ្រប់ដំណាក់កាលបានឆ្លើយឱ្យដឹងថា ពួកខ្លួនបានចូលលុយគ្នាទិញគ្រឿងញៀនពីឈ្មោះ [redacted] Ke ចំនួន ៣០ ហ៊ុន ដោយក្នុងមួយហ៊ុនតែតម្លៃ ២៧ ដុល្លារ ហើយពួកខ្លួនលក់ចេញវិញ ០១ ហ៊ុនតម្លៃ ៥០ ដុល្លារ ។
  - ជាមួយគ្នានេះ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] Ke គឺបានដកហូតសារធាតុញៀន ពីរូបគេមានចំនួនច្រើនផងដែរ នេះសបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទរូបនេះ ពិតជាបានប្រព្រឹត្តបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។

- **អំពើជនជាប់ចោទឈ្មោះ [redacted] Cheng Xiang និងឈ្មោះ [redacted] Yi ៖**
  - តាមចម្លើយរបស់ជនជាប់ចោទទាំងពីររូបនេះ នាពេលសវនាការបានឆ្លើយបដិសេធថា ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ពួក

ខ្លួនគ្រាន់តែទិញគ្រឿងញៀនយកមកប្រើប្រាស់តែប៉ុណ្ណោះ តែចម្លើយដោះសារបែបនេះ មិនអាចឱ្យតុលាការជឿជាក់បានទេ ដោយហេតុថា ផ្អែកតាមចម្លើយរបស់ជនជាប់ចោទទាំងពីររូបនេះ នៅដំណាក់កាលសមត្ថកិច្ច និងនៅដំណាក់កាលចៅក្រមស៊ើបសួរបានឆ្លើយសារភាពថា ពួកខ្លួនបានចូលលុយគ្នាទិញគ្រឿងញៀនពីជនជាតិចិន នៅម៉ុំភ្នំខៀវ និងទិញពីឈ្មោះ [redacted] Ke ដោយទិញក្នុងមួយលើកៗ ចំនួន ២០ ហ៊ុន ទៅ ៣០ ហ៊ុន ក្នុងមួយហ៊ុន គេលក់ឱ្យតម្លៃ ៣០ ដុល្លារ ហើយខ្លួនលក់ចេញវិញបានក្នុងមួយហ៊ុនស្មើនឹង ៥០ ដុល្លារ ។

- ទន្ទឹមនឹងនេះ នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួនជនជាប់ចោទទាំងពីររូបនេះ គឺបានដកហូតសារធាតុញៀនពីពួកគេមានចំនួនច្រើន និងច្រើនប្រភេទផងដែរ ដូចមានបញ្ជាក់នៅក្នុងកំណត់ហេតុដកហូតសម្ភារៈវត្ថុតាងចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលអាចឱ្យតុលាការយល់ឃើញថា ពុំមែនជារូបភាពនៃការទិញគ្រឿងញៀនយកមកប្រើប្រាស់ទេ គឺស្តែងឱ្យឃើញពីការចែកចាយគ្រឿងញៀន ប៉ុន្តែជនជាប់ចោទបានឆ្លើយបដិសេធ ដើម្បីឱ្យរួចផុតពីទោសតែប៉ុណ្ណោះ ។

- **អំពើជនជាប់ចោទឈ្មោះ [redacted] Qing Gen ៖**
    - តាមចម្លើយរបស់ជនជាប់ចោទរូបនេះ នៅគ្រប់ដំណាក់កាល និងនាពេលសវនាការបានឆ្លើយបញ្ជាក់ថា ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ [redacted] Chen Xiang និងឈ្មោះ [redacted] Yi បានចំនួន ០៣ លើកមកហើយ ហើយនៅពេលដែល សមត្ថកិច្ចឃាត់ខ្លួន គឺខ្លួនកំពុងតែស្នាក់នៅក្នុងផ្ទះសំណាក់ជាមួយឈ្មោះ [redacted] Chen Xiang និងឈ្មោះ [redacted] Yi ។
    - ការដែលជនជាប់ចោទរូបនេះ ស្នាក់នៅក្នុងបន្ទប់ជាមួយឈ្មោះ [redacted] Chen Xiang និងឈ្មោះ Chen Yi ហើយបានដឹងថា ឈ្មោះ [redacted] Chen Xiang និងឈ្មោះ [redacted] Yi ជាអ្នករកស៊ីជួញដូរគ្រឿងញៀនរួចទៅហើយ ដោយជនជាប់ចោទរូបនេះ មិនបានរាយការណ៍ទៅសមត្ថកិច្ចឡើយ ថែមទាំងទិញគ្រឿងញៀនពីឈ្មោះ [redacted] Chen Xiang និងឈ្មោះ [redacted] Yi ជាច្រើនលើក យកមកប្រើប្រាស់ថែមទៀត ។ ទង្វើរបស់ជនជាប់ចោទរូបនេះ គឺ

មានចេតនាជួយសម្រួលដល់ការប្រព្រឹត្តបទល្មើសរបស់ឈ្មោះ [redacted] Chen Xiang និងឈ្មោះ [redacted] ប្រាកដមែន ។ មួយវិញទៀត នៅពេលដែលសមត្ថកិច្ចចុះទៅឃាត់ខ្លួនរូបគេ ក៏បានដកហូតថ្នាំញៀនចំនួន ០៣ កញ្ចប់ពីរូបគេផងដែរ ដែលសកម្មភាពខាងលើនេះ គឺជាបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

៣.៦ តាមលិខិតលេខ **១៩៦៥៤/១៩ ម.ព.អ.ជ.ប.គ.ញ** ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិកាដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់លទ្ធផលកោសល្យវិច័យលើសំណាកគ្រឿងញៀនរបស់ឈ្មោះ **Yang Ke** និងឈ្មោះ [redacted] **Liang** ៖

- **សំណាកទី១** គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ស្ថិតនៅតារាងទី៣ មាត្រា ៥ មានបរិមាណសុទ្ធ ៥៩.៦៥ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ៤៩៩,៤៨ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (៤៩៩,៤៨ក្រាម X ៥៩,៦៥/១០០)= ២៩៧,៩៣ ក្រាម សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ កថាខណ្ឌ ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- **សំណាកទី២** គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ស្ថិតនៅតារាងទី៣ មាត្រា ៥ មានបរិមាណសុទ្ធ ៥៩,៦៥ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ១២.៤២ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (១២.៤២ ក្រាម X ៥៩.៦៥/១០០)= ៧.៤០ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- **សំណាកទី៣** ជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រា អាយ ឬ ម៉ាទឹកកក) ស្ថិតនៅតារាងទី២ មាត្រា ៥ មានបរិមាណសុទ្ធ ៨០.៣៤ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ២៦៦.៣១ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (២៦៦.៣១

ក្រាម X ៨០.៣២១០០)= ២១៣.៩៥ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤០ កថាខណ្ឌ ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៧ តាមលិខិតលេខ **១៩៦៥៥/១៩** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់លទ្ធផលកោសល្យវិច័យលើសំណាកគ្រឿងញៀនរបស់ឈ្មោះ [redacted] **Qing Gen** ថា ជាប្រភេទម្សៅឈ្មោះ កេតាមីន ស្ថិតនៅក្នុងតារាងទី៣ មាត្រា ៥ មានបរិមាណសុទ្ធ ៥៩,៦៥ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ១,៩៣ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (១,៩៣ ក្រាម X ៥៩.៦៥/១០០)= ១.១៥ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៨ តាមលិខិតលេខ **១៩៦៥៦/១៩** ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់លទ្ធផលកោសល្យវិច័យលើសំណាកគ្រឿងញៀនរបស់ឈ្មោះ [redacted] **Xi** និងឈ្មោះ [redacted] **Cheng Xing** ៖

- **សំណាកទី១** ជាគ្រឿងញៀនប្រភេទម្សៅឈ្មោះ កេតាមីន ស្ថិតនៅក្នុងតារាងទី៣ មាត្រា ៥ មានបរិមាណសុទ្ធ ៥៩,៦៥ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ១០២,៩២ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (១០២.៩២ ក្រាម X ៥៩,៦៥/១០០)= ៦១,៣៩ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- **សំណាកទី២** ជាគ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ មេតំហ្វេតាមីន (ហៅក្រោយ៉ាបា ឬថ្នាំឆ្កួត) ស្ថិតនៅក្នុងតារាងទី២ មាត្រា ៥ មានបរិមាណសុទ្ធ ២៤,៣៩ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់

សរុប ០.១៨ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (០.១៨ ក្រាម X ៤៤,៣៩/១០០)= ០.០៤ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤០ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- ***សំណាកទី៣*** អវិជ្ជមាន គ្មានវត្តមានសារធាតុញៀន ឬ សារធាតុគីមីផ្សំទេ
- ***សំណាកទី៤*** ជាគ្រឿងញៀនប្រភេទក្រាមម្សៅដែលមានផ្ទុកសារធាតុញៀន ចំនួន ០២ (ពីរ) ប្រភេទ៖

***-ទី១ ឈ្មោះ កេតាមីន*** ស្ថិតនៅក្នុងតារាងទី៣ មាត្រា ៥ មានបរិមាណសុទ្ធ ៦,៧៦ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ៥.៦៦ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (៥,៦៦ ក្រាម X ៦,៧៦/១០០)= ០,៣៨ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤៨ កថាខណ្ឌ ៤ នៃច្បាបស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

***-ទី២ ឈ្មោះ អឹម ដេ អឹម អា*** ស្ថិតនៅក្នុងតារាងទី១ មាត្រា ៥ មានបរិមាណសុទ្ធ ១៨,២៨ ភាគរយនៃទម្ងន់សរុប ដូច្នេះថ្នាំញៀនដែលបានដកហូតមានទម្ងន់សរុប ៥.៦៦ ក្រាម ត្រូវមានបរិមាណសរុបស្មើនឹង (៥,៦៦ ក្រាម X ១៨.២៨/១០០)= ១.០៣ ក្រាម ។ សកម្មភាពល្មើសទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតនេះ មិនត្រូវបានចែងជាពិសេសទេ ដូច្នេះមានន័យថា មានកំណត់នៅក្នុងផ្នែកទូទៅនៃមាត្រា ៤០ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.៩ យោងតាមលិខិតលេខ ១៩៦៥៤/១៩ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិកាដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានផ្តល់លទ្ធផលនៃការធ្វើកោសល្យវិច័យថា គ្រឿងញៀនដែលសមត្ថកិច្ចបានដកហូតពីឈ្មោះ [redacted] Ke និងឈ្មោះ [redacted] Liang មានបរិមាណសុទ្ធច្រើន ហើយបរិមាណសុទ្ធក្នុងកំរិតនេះ ត្រូវបានចែងនៅក្នុងមាត្រា

៤០ កថាខណ្ឌ ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប៉ុន្តែត្រង់ចំណុចខាងលើនេះ តុលាការមិនអាចលើកយកមកពិចារណាបានទេ ដោយហេតុថាផ្អែកតាមការសួរចម្លើយ និងចម្លើយរបស់ជនជាប់ចោទទាំងពីររូបនេះ នៅក្នុងកំណត់ហេតុស្តីពីការតទល់ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ បានរំលេចឱ្យឃើញថា ការឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] Liang និងឈ្មោះ [redacted] Ke គឺនៅពេលវេលា និងទីកន្លែងខុសគ្នា ផ្ទុយមកវិញចំពោះកំណត់ហេតុដកហូតវត្ថុតាង សមត្ថកិច្ចបែរជាឱ្យជនជាប់ចោទទាំងពីររូបនេះ ទទួលស្គាល់រួមគ្នា ដូច្នេះតុលាការយល់ឃើញថា សកម្មភាពល្មើសដែលទាក់ទងនឹងសារធាតុញៀនដែលមានបរិមាណសុទ្ធក្នុងកំរិតខាងលើនេះ ត្រូវកំណត់ក្នុងមាត្រា ៤០ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.១០ យោងតាមសំអាងហេតុខាងលើ ពិតជាបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] **Liang** , ឈ្មោះ [redacted] **Ke** , ឈ្មោះ [redacted] **Cheng Xiang** និងឈ្មោះ [redacted] **Yi** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៤ និងមាត្រា ៤៨ **កថាខណ្ឌ** ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **Qing Gen** ពីបទ **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **៤៨ កថាខណ្ឌ** ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣.១១ វត្ថុតាងរួមមាន: គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់ធំ ទម្ងន់ ៤៩៩.៤៨ ក្រាម , គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១៦,៤២ ក្រាម , គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន ចំនួន ០១ កញ្ចប់ ទម្ងន់ ២៦៦.៣១ ក្រាម , គ្រឿងញៀន ប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១០២.៩២ ក្រាម , គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ មេតំហ្វេតាមីន (WY) ចំនួន ១២ គ្រាប់ ទម្ងន់ ០.១៨ ក្រាម , កញ្ចប់ផ្លាស្ទិច



Scanned with CamScanner

ពណ៌ស្វាយ ០១ កញ្ចប់ (គ្មានសារធាតុញៀន) ទម្ងន់ ៤០,៦៧ ក្រាម , គ្រឿងញៀនប្រភេទក្រាមម្សៅផ្ទុកសារធាតុញៀនចំនួន ០២ ប្រភេទគឺឈ្មោះ កេតាមីន និងឈ្មោះ មេតំហ្វេតាមីន ចំនួន ០២ កញ្ចប់ ទម្ងន់ ៥,៦៦ ក្រាម , ជញ្ជីងសម្រាប់ថ្លឹងចំនួន ០២ , ថង់សម្រាប់វេចខ្ចប់គ្រឿងញៀនចំនួន ០៦ ដុំ , គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១,៩៣ ក្រាម , ទូរស័ព្ទដៃចំនួន ០៣ គ្រឿង (ម៉ាក Huawei , ម៉ាក Vivo , និងម៉ាក Oppo ) ដែលជាប់ពាក់ព័ន្ធនឹងបទល្មើស គប្បីតុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។ ដោយឡែករថយន្តចំនួន ០៣ គ្រឿង (ម៉ាក Rx 300 ,ម៉ាក Prius ពណ៌ទឹកប្រាក់ និងម៉ាក Lx 300 ពណ៌ ស ) ដែលពុំជាប់ពាក់ព័ន្ធនឹងបទល្មើស គប្បីតុលាការសម្រេចប្រគល់ឱ្យទៅម្ចាស់ដើមយកទៅប្រើប្រាស់ធ្វើជាម្ចាស់កម្មសិទ្ធិវិញ ។

៣.១២ តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរ និងសុំឱ្យតុលាការមេត្តាសម្រេចផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់ ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៣ មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សូមតុលាការមេត្តាសម្រេចឱ្យឈ្មោះ [redacted] Liang រួចផុតពីបទចោទ និងដោះលែងកូនក្តីខ្ញុំឱ្យមានសេរីភាពវិញ និងសូមតុលាការមេត្តាសម្រេចប្តូរបទចោទលើកូនខ្ញុំឈ្មោះ [redacted] Qing Gen ពីបទ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកជាបទ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន វិញ ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៤ មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សូមតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យកូនក្តីខ្ញុំផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៥ មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សូមតុលាការមេត្តាលើកលែងចោទប្រកាន់ឱ្យកូនក្តីខ្ញុំផង ។ គប្បីតុលាការលើកយកមកពិចារណា ។

៣.១៦ មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សូមឱ្យតុលាការមេត្តាពិចារណាលើស្ថានសម្រាលទោសលើកូនក្តីខ្ញុំផង ។

៣.១៧ ជនជាប់ចោទបាននិយាយសំដីចុងក្រោយថា សូមតុលាការបន្ធូរបន្ថយទោសឱ្យពួកខ្លួនផង ។ គប្បីតុលាការលើកយកមកពិចារណា ។

## ៤.ផ្នែកសេចក្តីសម្រេច ៖

## ហេតុដូច្នេះសាលាដំបូងខេត្តព្រះសីហនុ

## វិនិច្ឆ័យសេចក្តី

៤.១ ផ្តន្ទាទោសលើៈ

៤.១.១ ឈ្មោះ [redacted] លៀង [redacted] LIANG) ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិចិនដីគោក និងឈ្មោះ [redacted] ខឺ ([redacted] KE) ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិចិនដីគោក (មានសារតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤,០០០,០០០ (បួនលាន) រៀល ៖

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៤ និងមាត្រា ៤៨ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.១.២ ឈ្មោះ [redacted] ឆេងយ៉ាង ([redacted] CHENG XIANG) ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិចិនដីគោក និងឈ្មោះ [redacted] អ៊ី ([redacted] YI) ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិចិន (មានសារតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤,០០០,០០០ (បួនលាន) រៀល ៖

ពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៤ និងមាត្រា ៤៨ កថាខណ្ឌ ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៤.១.៣ ឈ្មោះ [redacted] ស៊ិងកិន [redacted] QING GEN) ភេទប្រុស អាយុ ៤៤ឆ្នាំ ជនជាតិចិន (មានសារតារជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៤,០០០,០០០ (បួនលាន) រៀល ៖

ពីបទ: **សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ៤ ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤៨ កថាខណ្ឌ ២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៤.២ បង្គាប់មកមន្ត្រីមានសមត្ថកិច្ចអនុវត្តនីតិវិធីបណ្តេញចេញជនជាប់ចោទឈ្មោះ [redacted] លៀង [redacted] LIANG) , ឈ្មោះ [redacted] ខឺ (YANG KE) , ឈ្មោះ [redacted]ឆេងយ៉ាង (HU [redacted] XIANG) , ឈ្មោះ [redacted] អ៊ី (CHEN YI) និងឈ្មោះ [redacted] សិងគិន ([redacted] QING GEN) ពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសដើមវិញ បន្ទាប់ពីអនុវត្តទោសចប់ជាស្ថាពរ ។

៤.៣ វត្ថុតាងរួមមាន៖

- គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់ធំ ទម្ងន់ ៤៩៩.២៨ ក្រាម ។
- គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១២.៤២ ក្រាម ។
- គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន ចំនួន ០១ កញ្ចប់ ទម្ងន់ ២៦៦.៣១ ក្រាម ។
- គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១០២.៩២ ក្រាម ។
- គ្រឿងញៀនប្រភេទគ្រាប់ឈ្មោះ មេតំហ្វេតាមីន (WY) ចំនួន ០២ គ្រាប់ ទម្ងន់ ០.១៨ ក្រាម ។
- កញ្ចប់ផ្លាស្ទិចពណ៌ស្វាយ ០១ កញ្ចប់ (គ្មានសារធាតុញៀន) ទម្ងន់ ៤០.២៧ ក្រាម ។
- គ្រឿងញៀនប្រភេទក្រាមម្សៅផ្ទុកសារធាតុញៀនចំនួន ០២ ប្រភេទគឺ ឈ្មោះ កេតាមីន និងឈ្មោះ មេតំហ្វេតាមីន ចំនួន ០២ កញ្ចប់ ទម្ងន់ ៥.៦៦ ក្រាម ។
- ជញ្ជីងសម្រាប់ថ្លឹងចំនួន ០២ ។
- ថង់សម្រាប់វេចខ្ចប់គ្រឿងញៀន ចំនួន ០៦ ដុំ ។

- គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ កេតាមីន ចំនួន ០១ កញ្ចប់តូច ទម្ងន់ ១.៩៣ ក្រាម ។
- ទូរស័ព្ទដៃចំនួន ០៣ គ្រឿង (ម៉ាក Huawei , ម៉ាក Vivo , និងម៉ាក Oppo ) ។

*ត្រូវរឹបអូស និងបំផ្លាញចោល ។*

- រថយន្តចំនួន ០៣ គ្រឿង (ម៉ាក Rx 300 ,ម៉ាក Prius ពណ៌ទឹកប្រាក់ និង ម៉ាក Lx 300 ពណ៌ស ) ។

ប្រគល់ឱ្យទៅម្ចាស់ដើមយកទៅប្រើប្រាស់ធ្វើជាម្ចាស់កម្មសិទ្ធិវិញ ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]លៀង (HAI LIANG) , ឈ្មោះ [redacted] ខឺ ([redacted]KE) , ឈ្មោះ [redacted]ឆេងយ៉ាង [redacted]CHENG XIANG) , ឈ្មោះ[redacted]អ៊ី (CHEN YI) និងឈ្មោះ [redacted] សិងកិន [redacted]QING GEN) ។ ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជី** | **ក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

[redacted]

[redacted]

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០២០
ក្រឡាបញ្ជី

[redacted]



Scanned with CamScanner